# អំពីក្រមប្រតិបត្តិ SBS



SBS គឺជាសេវាកម្មទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថលសាធារណៈជាតិដែលឯករាជ្យ មានការទទួលខុសត្រូវចំពោះសហគមន៍អូស្ត្រាលី ដូចមានចែងក្នុងធម្មនុញ្ញរបស់យើង។ យើងត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី និងប្រាក់ចំណូលពាណិជ្ជកម្ម ដូចជាការផ្សាយពាណិជ្ជកម្ម។

នៅទូទាំងបណ្តាញរបស់យើង យើងចែករំលែកការនិទានរឿងប្លែកៗរបស់អូស្ត្រាលី ព័ត៌មានក្នុងស្រុក និងអន្តរជាតិ ហើយនិងព្រឹត្តិការណ៍បច្ចុប្បន្ន កីឡា ល្ខោនអន្តរជាតិ និងឯកសារភាពយន្ត អាហារ ខ្សែភាពយន្ត និងសេវាកម្មវិទ្យុក្នុងស្រុកជាង 60 ភាសា។ យើងក៏ជាលំនៅដ្ឋាននៃការនិទានរឿងរបស់ប្រជាជាតិដំបូងផងដែរ ជាមួយទូរទស្សន៍ជាតិសម្រាប់ជនជាតិដើម (NITV) ដែលផ្តល់កម្មវិធីតាមរយៈកែវឆ្លុះរបស់ជនជាតិដើម។

ដើម្បីធានាថា មាតិការបស់យើងឆ្លើយតបទៅនឹងការរំពឹងទុករបស់សហគមន៍ យើងមានក្រមប្រតិបត្តិ SBS ដែលចែងពីវិធាន និងស្តង់ដារសម្រាប់មាតិកា SBS ទាំងអស់ មិនថាអ្នកចូលមើលពីកន្លែងណាទេ - តាមទូរទស្សន៍ វិទ្យុ អនឡាញ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម។

## ក្រមប្រតិបត្តិគ្របដណ្តប់បញ្ហាសំខាន់ៗដូចជា៖

### ទំនុកចិត្ត

**របៀបដែលយើងផ្តល់មាតិកាដែលគួរឱ្យទុកចិត្ត និងពាក់ព័ន្ធ**

- យើងធ្វើការសម្រេចចិត្តឯករាជ្យ អំពីមាតិការបស់យើង។
- មាតិកាព័ត៌មាន និងព្រឹត្តិការណ៍បច្ចុប្បន្នរបស់យើងគឺត្រឹមត្រូវ មានតុល្យភាព និងមិនលំអៀង ហើយជាផលប្រយោជន៍សាធារណៈ។.
- យើងទទួលយកទស្សនៈ និងការយល់ឃើញទូលំទូលាយ - មាតិការបស់យើងអាចមានលក្ខណៈច្នៃប្រឌិត ហើយមានការសួរដេញដោល ក៏ដូចជាការប្រជែងប្រឆាំង និងបង្កហេតុផងដែរ។

### តម្លាភាព

**វិធីដែលយើងជួយណែនាំជម្រើសមាតិការបស់អ្នក**

- យើងផ្តល់ជូនព័ត៌មាន ដើម្បីឱ្យអ្នកអាចជ្រើសរើសមាតិកាដែលសមត្រូវនឹងអ្នក និងក្មេង ហើយនិងមនុស្សវ័យក្មេងណាម្នាក់នៅក្រោមការថែទាំរបស់អ្នក។
- យើងត្រូវប្រាកដថា ការផ្សាយពាណិជ្ជកម្មគឺខុសប្លែកពីមាតិការបស់យើង និងកំណត់វិធាននានាអំពីការដាក់សម្រាប់ការផ្សាយពាណិជ្ជកម្មប្រភេទជាក់លាក់។
- ចំពោះមាតិកាដែលអាចនាំឱ្យកើតមានទុក្ខព្រួយ យើងពិចារណាដល់ទស្សនិកជន អនុវត្តដោយមានការថ្លឹងថ្លែង ផ្តល់ជូនការព្រមានកន្លែងណាដែលសមស្រប ហើយបង្ហាញតែអត្ថបទនោះប្រសិនបើវាពាក់ព័ន្ធនឹងវិចារណកថានៃការនិពន្ធ។

### គោរព

**របៀបដែលយើងអនុវត្ត និងលើកកម្ពស់ការគោរព**

- យើងចៀសវាងមាតិកាដែលលើកកម្ពស់ភាពលំអៀង និងការរើសអើង រួមទាំងការប្រើការសន្មតជាតួយ៉ាងមិនសមហេតុផលដោយគិតពីបរិបទ។
- យើងផ្តល់មាតិកាជាភាសានានាក្រៅពីភាសាអង់គ្លេស ហើយលើកទឹកចិត្តឱ្យមានការបញ្ចេញមតិទូលំទូលាយ។
- យើងមានភាពរសើបចំពោះការបង្ហាញពីបញ្ហាជនជាតិដើម ហើយសង្កេតមើលពិធីសារវប្បធម៌របស់ ជនជាតិដើម និងអ្នកកោះ Torres Strait។
- យើងគោរពភាពឯកជនរបស់មនុស្ស ដែលយើងថ្លឹងថ្លែងទល់នឹងទំនួលខុសត្រូវនៃការរាយការណ៍របស់យើង។

### ភាពទទួលខុសត្រូវ

**របៀបដែលយើងទទួលខុសត្រូវ**

- យើងផ្តល់ជូនអ្នកនូវវិធីនានាដើម្បីផ្តល់មតិយោបល់កែលម្អអំពីមាតិកា និងសេវាកម្មរបស់យើង ទោះជាការសរសើរ ឬរិះគន់ក្តី។
- យើងមានដំណើរការឯករាជ្យសម្រាប់បណ្តឹងតវ៉ាក្រោមក្រមប្រតិបត្តិ ដែលត្រូវបានស៊ើបអង្កេតដោយ អាជ្ញាធរស៊ើបអង្កេត និងទទួលបណ្តឹងតវ៉ាសាធារណៈ SBS។




SBS

ស្វែងយល់បន្ថែមទៀត

sbs.com.au/aboutus/sbs-code-of-practice